រ ដ្ឋ ក ម្ពុ ជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

៣*១

ក្រ ស ួ ង ក សិ ក ម្ម

លេខ : ០០៦៧ ប្រក.កសក

# ប្រ ក ា ស

## ស្តីពី

## ការកំណត់នាទីព្រៃ ដែលជាដែនទេសាទ

## ទឹកសាប និង សមុទ្រ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពី អង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពី សមត្ថកិច្ច និង និតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញា ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ការគ្រប់-គ្រងវិស័យផលផល ។
- បានឃើញអនុក្រឹត្យលេខ ១៨ អ.ន.ក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពី តួនាទី - ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ជំនួយអោយសេចក្តីកំណត់លេខ ៨៥-៨០កប ចុះថ្ងៃទី ០៩-០២-៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ពីមុន ។
- តាមសំណើរបស់នាយកដ្ឋានផលផល ,

## ស ំ រេ ច

មាត្រា ១ : នាទីព្រៃដែលត្រូវបានកំណត់ជាដែនទេសាទទឹកសាប និង សមុទ្រ ហើយដែលត្រូវរក្សាទុកសំរាប់បង្កបង្កើនផល ពិសេសសំរាប់ជាកន្លែងពងកូនរបស់ពពួកសត្វក្នុងទឹក មានដូចខាងក្រោម :-

១- នាទីព្រៃលិចទឹកទាំងអស់ ដែលស្ថិតនៅក្នុងឡូត៍នេសាទទឹកសាប ។

២- នាទីព្រៃលិចទឹកដែលបានកំណត់ព្រំប្រទល់តាមផែនទី ដូចមានភ្ជាប់ជាមួយ ចំពោះតំបន់ជុំ-វិញបឹងទន្លេសាប ។

៣- នាទីព្រៃទាំងអស់ នៅតាមតំបន់ឆ្នេរសមុទ្រ ដែលមានផ្ទៃទឹកលាតសន្ធឹងទៅដល់នៅពេលទឹកជោរ ។

មាត្រា ២ : ការប្រគល់សិទ្ធិផ្សេងៗលើដី នៅក្នុងនាទីឡូត៍នេសាទ ត្រូវមានសេចក្តីកំណត់ពីក្រសួងកសិកម្មតាមរយៈនាយកដ្ឋានផលផលជាមុន ។

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ការកាប់ ឆ្ការ រាន ឬ ដុតព្រៃឈើមានខ្លឹមក្នុងមាត្រា ១ការដឹកជញ្ជូន ការធ្វើសន្និធិ ឬ ការលក់ ទិញ ដូរ ឬ ឆ្លង នូវប្រភេទព្រៃខាងលើ និង ការភាគដីដើម្បីបំពីការដាំដុះ ឬ បំពីផលប្រយោជន៍ផ្សេងៗទៀត ក្នុងទាធីព្រៃខាងលើ ត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម តាមសំណើរបស់នាយកដ្ឋានផលផល ។

ប្រការ ៣ : ជនណាដែលកាប់ ឆ្ការ រាន ដុតព្រៃ ឬ ភាគដី ដែលស្ថិតនៅក្នុងទាធីព្រៃឈើមានខ្លឹមក្នុងមាត្រា ១ ដោយគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម គឺ ល្មើសនឹងមាត្រា ១៨ ក្រង់ចំណុច "ឃ" ត្រូវផ្តន្ទាទោសតាមមាត្រា ៣៧ នៃក្រឹត្យ ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ការគ្រប់គ្រងវិស័យផលផល ។

ជនណាដែលដឹកជញ្ជូន ធ្វើសន្និធិ លក់ ឬ ទិញ ដូរ ឆ្លង នូវប្រភេទព្រៃឈើមានខ្លឹមក្នុងមាត្រា ១ ដោយគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម គឺ ល្មើសនឹងមាត្រា ១៨ ក្រង់ចំណុច "ង" ត្រូវផ្តន្ទាទោសតាមមាត្រា ៣៦ នៃក្រឹត្យ ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ការគ្រប់គ្រងវិស័យផលផល ។

បើការប្រព្រឹត្តនោះចូលក្នុងករណីមិនរាងចាល ឬ បង្កឡើងអោយមានអន្តរាយធ្ងន់ធ្ងរដល់ធនធានផលផល ត្រូវផ្តន្ទាទោសតាមមាត្រា ៣៩ នៃក្រឹត្យ ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ការគ្រប់គ្រងវិស័យផលផលបន្ថែមទៀត ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង មន្ទីរ ក្រសួងកសិកម្ម នាយកដ្ឋានផលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៦ : ប្រកាសនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ភ្នំពេញ,ថ្ងៃទី ០៧ ខែ ០៩ ឆ្នាំ ១៩៨៩
រដ្ឋមន្ត្រីក្រសួង កសិកម្ម
ហត្ថលេខា និងត្រា : សាយ ឈុំ

លេខ ៥៨ សរ.សរ.ណា
បានឃើញ និងយល់ព្រម
ភ្នំពេញ,ថ្ងៃទី ០៨ ខែ ០៩ ឆ្នាំ ១៩៨៩
ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និងត្រា : គង់ សំអុល

កន្លែងទទួល :
- ខុទ្ទកាល័យមជ្ឈិមបក្ស
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋ
- គ្រប់ក្រសួង មន្ទីរជុំវិញមជ្ឈិម

"ដើម្បីជូនដំណឹង"

- គ្រប់អង្គភាពក្នុងបន្ទុកក្រសួងកសិកម្ម

"ដើម្បីជ្រាប"

- ដូចមាត្រា ៥

"ដើម្បីអនុវត្ត"

- ឯ ក សា រ
- កា លប្ប វ ត្តិ